ធ៧-០១០-១៨២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាមូលនិធិផ្ទាល់សុទ្ធ របស់ធនាគារ

**ប្រការ ១**.-

គ្រឹះស្ថានធនាគារត្រូវគណនាមូលនិធិផ្ទាល់សុទ្ធឱ្យស្របតាមបទប្បញ្ញត្តិនៃប្រកាសនេះ។ រាល់អនុបាត និងកម្រិតកំណត់ប្រុងប្រយ័ត្នដែលទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ ត្រូវគណនាឱ្យស្របតាមវិធាននៃការគណនា នេះ។ លើសពីនេះ ដើមទុនឬទាយជ្ជទានដែលបានបង់ និងមូលនិធិផ្ទាល់សុទ្ធត្រូវតែស្មើ ឬលើសពីដើមទុន អប្បបរមាដែលត្រូវបានអនុវត្តចំពោះគ្រឹះស្ថាននោះ។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារត្រូវបង្កើតគោលនយោបាយ នីតិវិធី និងដំណើរការត្រួតពិនិត្យផ្ទៃក្នុង សំដៅធានា ការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវកាតព្វកិច្ចជាបទបញ្ជាទាំងអស់ ទាក់ទងនឹងអនុបាតសាធនភាពអប្បបរមា និង កម្រិតកំណត់ដែលទាក់ទងនឹងមូលនិធិផ្ទាល់សុទ្ធ។

**ប្រការ ៣**.-

ធនាគារជាតិនៃកម្ពុជា អាចតម្រូវឱ្យគ្រឹះស្ថានធនាគារអនុវត្តនីតិវិធីពិសេស ក្រោមរូបភាពជាការដកចេញ នូវខ្ទង់មួយចំនួនថែមទៀតពីការគណនាមូលនិធិផ្ទាល់សុទ្ធ ដោយមិនគិតដល់វិធានទូទៅនៃការគណនាដូចមាន ចែងនៅក្នុងប្រកាសនេះ។ ការអនុវត្តនីតិវិធីពិសេសនេះគឺ ដើម្បីស្តារឡើងវិញនូវការប្រតិបត្តិតាមបទបញ្ជា និង ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញហានិភ័យជាក់ស្តែងនិងហានិភ័យជាសក្តានុពល ក្នុងគោលបំណងប្រុងប្រយ័ត្ន។

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការអនុវត្តនីតិវិធីពិសេសនេះ ហើយ គ្រឹះស្ថានធនាគារត្រូវអនុវត្តតាមភ្លាម រហូតដល់មានការណែនាំផ្សេងជាលាយលក្ខណ៍អក្សរ។

**ប្រការ ៤**.-

មូលនិធិផ្ទាល់សុទ្ធសរុបមានសមាសធាតុ ២ ដាច់ដោយឡែកពីគ្នាគឺ ៖

- ដើមទុនថ្នាក់ទីមួយ (ដើមទុនស្នូល) និង
- ដើមទុនថ្នាក់ទីពីរ (ដើមទុនបំពេញបន្ថែម)

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយទេ ឬ មិនត្រូវលើសពី ៥០% នៃមូលនិធិ ផ្ទាល់សុទ្ធសរុបឡើយ ។

មុននឹងចេញរបាយការណ៍ពាក់ព័ន្ធ ធនាគារត្រូវពិនិត្យ ផ្ទៀងផ្ទាត់ ដើម្បីធានាការប្រតិបត្តិតាមកម្រិត កំណត់នេះ ។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ធនាគារជាតិនៃកម្ពុជានឹងមានវិធានការសមស្រប។

**ប្រការ ៥**.-

ដើមទុនថ្នាក់ទីមួយ ត្រូវគណនាដូចខាងក្រោម ៖

I- **សរុបរង** A: (**ខ្ទង់ត្រូវបូក**)

- ដើមទុន ឬទាយជ្ជទាន ដែលបានបង់
- ទុនបម្រុងដែលមិនមែនជាទុនបម្រុងដែលត្រូវបានវាយតម្លៃឡើងវិញ
- បុព្វលាភទាក់ទងនឹងដើមទុន (បុព្វលាភភាគហ៊ុន)
- ប្រាក់ចំណេញរក្សាទុកត្រឹមកម្រិត ២០% នៃសរុបរង A ។ ចំនួនលើសពី ២០% នៃសរុបរង A ធនាគារអាចសម្រេចរក្សាទុកជាទុនបម្រុង
- ប្រាក់ចំណេញសុទ្ធដែលត្រូវបានធ្វើសវនកម្មរួចហើយ សម្រាប់ឆ្នាំហិរញ្ញវត្ថុចុងក្រោយ
- លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏អាចអនុម័តខ្ទង់ផ្សេងទៀត ដែលត្រូវបញ្ចូលទៅក្នុងសរុបរង A ដូចជាប្រាក់ចំណេញដែលបានកត់ត្រានៅក្នុងការិយបរិច្ឆេទ លុះត្រាតែៈ ១-ប្រាក់ចំណេញនោះត្រូវបានកំណត់បន្ទាប់ពីដកចេញបន្ទុកចំណាយទាំងអស់នៅក្នុងរយៈពេលដូចគ្នា (ការរំលោះសំវិធានធន និងការកែតម្រូវតម្លៃសុទ្ធ) ២-ប្រាក់ចំណេញនោះត្រូវបានគណនាជាចំនួនសុទ្ធដោយដកចេញនូវចំនួនប្រាក់ពន្ធនិងភាគលាភដែលត្រូវសង ៣-ប្រាក់ចំណេញសុទ្ធនេះត្រូវបានបញ្ជាក់ពីសវនកររងករាជ្យ។

II- **សរុបរង** B: (**ខ្ទង់ត្រូវដក**)

- ភាគហ៊ុនផ្ទាល់ដែលកាន់កាប់ដោយធនាគារ តាមតម្លៃសុទ្ធចុះបញ្ជី
- ការខាតបង្គរ
- ទ្រព្យសកម្មអរូបិយ (ដូចជាតម្លៃកេរ្តិ៍ឈ្មោះ ... ជាដើម)
- ចំពោះភាគទុនិក គណៈនាយក និងភាគីសម្ព័ន្ធញ្ញាតិដូចមាននិយមន័យនៅក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ:
  . ចំណែកដើមទុន ឬទាយជ្ជទាន ដែលមិនទាន់បានបង់
  . ប្រាក់កម្ចី ឥណទានវិបារូបន៍ និងបុរេប្រទាន
  . ឧបករណ៍បំណុលដែលកាន់កាប់ដោយធនាគារតាមតម្លៃសុទ្ធចុះបញ្ជី (Net Book Value) ហើយមានហត្ថលេខារបស់បុគ្គលពាក់ព័ន្ធទាំងនោះ
- ការខាតក្នុងគ្រាប្រតិបត្តិការ ក្រៅពីការខាតនាចុងការិយបរិច្ឆេទប្រចាំឆ្នាំដែលរួមទាំងរាល់សំវិធានធនលើបំណុល និងមូលបត្រមិនដំណើរការ ក៏ដូចជាការកែតម្រូវដទៃទៀតសម្រាប់ការរំលោះនៅក្នុងរយៈពេលដូចគ្នា។ សំវិធានធននិងការរំលោះត្រូវស្របតាមបទបញ្ញាជាធរមានដោយផ្អែកលើការវាយតម្លៃដោយប្រុងប្រយ័ត្នលើហានិភ័យដែលពាក់ព័ន្ធ។

**ដើមទុនថ្នាក់ទីមួយ = សរុបរង A - សរុបរង B ។**

**ប្រការ ៦**.-

ដើមទុនថ្នាក់ទីពីរមិនត្រូវលើសពី ១០០%នៃដើមទុនថ្នាក់ទីមួយសម្រាប់គណនាមូលនិធិផ្ទាល់សុទ្ធសរុប។

ប្រសិនបើដើមទុនថ្នាក់ទីពីរលើសពីដើមទុនថ្នាក់ទីមួយ ដូចបានគណនាក្នុងប្រការ ៥ នៃប្រកាសនេះ ធនាគារមិនត្រូវយកចំនួនដែលលើសពី ១០០% នៃដើមទុនថ្នាក់ទីមួយនោះមកគណនាបញ្ចូលឡើយ។

III- **សរុបរង C: (ខ្ទង់ត្រូវបូក )**

- ការវាយតម្លៃទុនបម្រុងឡើងវិញដោយមានការយល់ព្រមជាមុន ជាលាយលក្ខណ៍អក្សរពីធនាគារជាតិនៃកម្ពុជា
- សំវិធានធនសម្រាប់ហានិភ័យទូទៅរបស់ធនាគារ ដោយមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា
- សំវិធានធនទូទៅ ១% ដែលបានកំណត់នៅក្នុងប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ឧបករណ៍បំណុលបន្ទាប់បន្សំមិនអាចលើសពី ៥០% នៃដើមទុនថ្នាក់ទីមួយ ហើយត្រូវបំពេញឱ្យបានគ្រប់លក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ខាងក្រោម
- ខ្ទង់ដទៃទៀតដែលមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា។

IV- **សរុបរង D: (ខ្ទង់ត្រូវដក )**

- ការចូលភាគកម្មតាមតម្លៃសុទ្ធចុះបញ្ជីនៅក្នុងគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ រួមទាំងក្រុមហ៊ុនមូលបត្រ
- ខ្ទង់ផ្សេងទៀត ដូចជាបន្ទុកចំណាយដែលត្រូវបង់។

**ដើមទុនថ្នាក់ទីពីរ = សរុបរង C - សរុបរង D ។**

**ប្រការ ៧**.-

៧.១ បំណុលបន្ទាប់បន្សំត្រូវមានឯកសារទ្រទ្រង់ រួមទាំងកិច្ចសន្យាផងដែរ។ កិច្ចសន្យានោះត្រូវមានបញ្ជាក់ច្បាស់ពីលំដាប់នៃម្ចាស់បំណុល (Subscriber) ដែលនៅខ្ពស់បន្ទាប់ពីភាគទុនិកធម្មតា កាលវសាន្ត និងលក្ខខណ្ឌផ្សេងទៀត។

៧.២ បំណុលបន្ទាប់បន្សំនេះអាចបញ្ចូលក្នុងដើមទុនថ្នាក់ទីពីរបាន លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា។

៧.៣ ធនាគារមិនត្រូវសងបំណុលបន្ទាប់បន្សំឱ្យវិនិយោគិនវិញដោយមិនមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជាឡើយ។ ប្រសិនបើធនាគារសម្រេចចិត្តសងបំណុលបន្ទាប់បន្សំដោយគ្មានការអនុញ្ញាតជាមុន ឥណទាយកមិនមែនជាម្ចាស់បំណុលបន្ទាប់បន្សំរបស់ធនាគារ ឬអាជ្ញាធរត្រួតពិនិត្យ ធនាគារអាចជំទាស់នឹងសំណងបែបនេះ។ ក្នុងករណីនេះ ម្ចាស់បំណុលដែលទទួលសំណងបំណុលបន្ទាប់បន្សំ មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងចំនួននោះត្រឡប់មកធនាគារវិញឡើយ នៅពេលមានការតម្រូវ។

៧.៤ ចំពោះឧបករណ៍បំណុលបន្ទាប់បន្សំ ដែលមានកំណត់កាលវសាន្តនៅពេលចុះកិច្ចសន្យា ធនាគារត្រូវអនុវត្តការសងរំលោះថេរប្រចាំឆ្នាំចំនួនមួយភាគប្រាំនៃបំណុលបន្ទាប់បន្សំ ចាប់ផ្តើមពីរយៈពេលប្រាំឆ្នាំមុនកាលវសាន្តនៃកិច្ចសន្យា។ ការសងរំលោះបែបនេះត្រូវធ្វើឡើងតាមដំណាក់កាល ដើម្បីឱ្យចំនួននៅក្នុងសរុបរង C ស្មើនឹងសូន្យនៅកាលវសាន្តនៃកិច្ចសន្យា។

៧.៥ ចំពោះឧបករណ៍បំណុលបន្ទាប់បន្សំ ដែលពុំមានកំណត់កាលវសាន្តនៅពេលចុះកិច្ចសន្យា ធនាគារត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា យ៉ាងហោចណាស់មុនប្រាំឆ្នាំ អំពីបំណងរបស់ខ្លួនក្នុងការសងបំណុលបន្ទាប់បន្សំទាំងនោះ។ ប្រសិនបើ ធនាគារជាតិនៃកម្ពុជាមិនជំទាស់ចំពោះការសងរំលោះនេះទេ ធនាគារត្រូវអនុវត្តការសងរំលោះថេរប្រចាំឆ្នាំចំនួនមួយភាគប្រាំនៃបំណុលបន្ទាប់បន្សំ ចាប់ផ្តើមពីរយៈពេលប្រាំឆ្នាំមុនកាលបរិច្ឆេទដែលត្រូវបានកំណត់ដើម្បីសងរំលោះបំណុលទាំងស្រុង។

៧.៦ ធនាគារជាតិនៃកម្ពុជាអាចនឹងសម្រេចផ្តល់ការអនុញ្ញាត ឬបដិសេធការសងរំលោះទាំងស្រុងនូវបំណុលបន្ទាប់បន្សំ ដោយផ្អែកលើស្ថានភាពហិរញ្ញវត្ថុជាទូទៅរបស់ធនាគារ។

**ប្រការ ៨**.-

ប្រកាសស្តីពី ដើមទុនអប្បបរមារបស់ធនាគារពាណិជ្ជ លេខ ធ៧-០០-៣៩ ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០ និង ប្រកាសស្តីពី ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ លេខ ធ៧-០០-៤៧ ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១០**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី១៥ ខែ តុលា ឆ្នាំ២០១០

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**